# សេចក្តីប្រកាសព័ត៌មាន

នាថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១០ វេលាម៉ោង ៩:០០ ព្រឹក នៅសាលប្រជុំនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានប្រារព្ធកិច្ចប្រជុំទ្វេភាគីរវាងរដ្ឋបាលគយកម្ពុជា ដឹកនាំដោយ ឯ.ឧ. បណ្ឌិត **ប៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា និងអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន ដឹកនាំដោយឯកឧត្តម **លី កេឈុខ** អនុរដ្ឋមន្ត្រីនៃអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងគោលបំណងពិភាក្សាគ្នាលើកិច្ចសហប្រតិបត្តិការលើវិស័យគយជាពិសេសកិច្ចសម្រួលពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ។ កិច្ចប្រជុំនេះ គឺជាផ្នែកមួយនៃដំណើរទស្សនកិច្ចជាផ្លូវការលើកទី ១ របស់គណៈប្រតិភូគយចិន រយៈពេល ៤ ថ្ងៃ មកកាន់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាមកកាន់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដែរ ។

នៅក្នុងកិច្ចប្រជុំនេះ បន្ទាប់ពីបានលើកឡើងអំពីវឌ្ឍនភាព និងសមិទ្ធផលសម្រេចបាននាពេលថ្មីៗនេះរបស់អង្គភាពរៀងខ្លួនមក និងដោយយល់ថាទំហំវិនិយោគទុនរបស់ចិននៅកម្ពុជា និងការផ្លាស់ប្តូរទំនិញរវាងប្រទេសទាំងពីរកាន់តែកើនឡើងជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃនោះ ភាគីទាំងពីរបានចុះហត្ថលេខា និងព្រមព្រៀងគ្នាដូចតទៅ ៖

១. ភាគីទាំងពីរនិងខិតខំអស់ពីលទ្ធភាពក្នុងការបន្តពង្រឹងថែមទៀតនូវកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមកលើបញ្ហាគយ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរៀងខ្លួន ដូចជាកិច្ចសម្រួលពាណិជ្ជកម្ម ដើមកំណើតទំនិញ ការបង្ការនិងបង្ក្រាបអំពើរត់ពន្ធទំនិញ និងគ្រឿងញៀន ព្រមទាំងបទល្មើសផ្សេងទៀត ពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មអន្តរជាតិរវាងប្រទេសទាំងពីរ ។

២. បន្តកែលម្អយន្តការនៃការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមក ស្តីពីនីតិវិធីគយ ទំនើបកម្មអង្គភាព បច្ចេកទេសគយ និងវឌ្ឍនភាពនានានៃការកសាងបទប្បញ្ញត្តិពាក់ព័ន្ធនឹងគយ ។

៣. បន្តជម្រុញការអនុវត្តកិច្ចព្រមព្រៀង GMS ស្តីពីកិច្ចសម្រួលការដឹកជញ្ជូនមនុស្ស និងទំនិញឆ្លងកាត់ព្រំដែន តាមរយៈការបង្កើតឲ្យមានកិច្ចប្រជុំរវាងថ្នាក់ដឹកនាំរដ្ឋបាលគយនៃបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ និងវិធានការផ្សេងទៀត ។

៤. ភាគីទាំងពីរបានព្រមព្រៀងថានឹងផ្តល់ការគាំទ្រគ្នាទៅវិញទៅមក នៅក្នុងវេទិកាគយពហុភាគី ដូចជា WCO, APEC, និង ASEM ជាដើម ។

៥. ដើម្បីបង្កើនកិច្ចសម្រួលពាណិជ្ជកម្ម និងកាត់បន្ថយបាតុភាពអសកម្មនានាពាក់ព័ន្ធនឹងបែបបទបញ្ចេញទំនិញពីគយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានបង្កើតយន្តការភាពជាដៃគូគយ-ផ្នែកឯកជន ដើម្បីដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងគយនានា ជាមួយផ្នែកឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមមានពាណិជ្ជករ និងវិនិយោគិនចិនផងដែរ ។

៦. កិច្ចប្រជុំទ្វេភាគីលើកទី ២ នឹងប្រព្រឹត្តទៅក្នុងពេលអនាគត នៅសាធារណរដ្ឋប្រជាមានិតចិន ដែលនឹងឈានទៅដល់ការបង្កើតអនុស្សរណៈនៃការយោគយល់គ្នាទៅវិញទៅមក ដែលជាប្បញ្ញត្តិបើកផ្លូវឲ្យរដ្ឋបាលគយទាំងពីរអាចពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការបានលើគ្រប់វិស័យ ប្រកបដោយប្រសិទ្ធភាព និងភាពយោគយល់គ្នា ។

កិច្ចប្រជុំទ្វេភាគីលើកទី ១ នេះ បានបញ្ចប់នាម៉ោង ១១:០០ ព្រឹក ថ្ងៃដដែល បន្ទាប់ពីពិធីចុះហត្ថលេខាលើខ្លឹមសារដែលបានព្រមព្រៀងគ្នាក្នុងកិច្ចប្រជុំ ក្រោមបរិយាកាសមិត្តភាព រីករាយ និងស្និទ្ធស្នាលក្រៃលែង ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១០